**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៨-១៩៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញា
# សម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment)
# និងប្រព័ន្ធខេមបូឌានស៊ែរស្វីច (Cambodian Shared Switch)

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី**
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៧-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជានិងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៧-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៧-០១៦-១៩៧ ប្រ.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីសមាជិកភាពប្រព័ន្ធ FAST និងប្រព័ន្ធ Central Shared Switch
- យោងប្រកាសលេខ ធ៧-០១៧-៣០៧ ប្រ.ក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើវិធាននិងនីតិវិធី Cambodian Shared Switch
- យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦

# សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ស្លាកសញ្ញារបស់ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ជាផ្លូវការសម្រាប់ប្រើប្រាស់នៅក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុដើម្បីជាសញ្ញាសម្គាល់ក្នុងការធ្វើប្រតិបត្តិការ និងអនុញ្ញាតឱ្យគ្រឹះស្ថានជាសមាជិកប្រព័ន្ធ ប្រើសម្រាប់អនុវត្តការងារពាក់ព័ន្ធ។

**ប្រការ ២.-**

ការកំណត់ស្លាកសញ្ញានេះក្នុងគោលដៅរក្សាសង្គតភាពក្នុងការប្រើប្រាស់ជាសាធារណៈ ធានាពីសិទ្ធិនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងការពារផលប្រយោជន៍របស់គ្រឹះស្ថានជាសមាជិកប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិការនិងការប្រើប្រាស់ស្លាកសញ្ញា ដែលពាក់ព័ន្ធនឹងប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកនៃប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ត្រូវរៀបចំ បោះពុម្ព និងប្រើប្រាស់ស្លាកសញ្ញាឱ្យបានត្រឹមត្រូវនិងមានលក្ខណៈស្តង់ដារ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៥.-**

រាល់ការក្លែងបន្លំ ការប្រើប្រាស់ស្លាកសញ្ញាទាំងនេះមិនបានត្រឹមត្រូវ និង/ឬដោយគ្មានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជានឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល ៖**

- ប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**

- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

# ឧបសម្ព័ន្ធ
# លក្ខណៈសម្គាល់ស្លាកសញ្ញា
# ប្រព័ន្ធសេវាទូទាត់រហ័ស ( Fast Payment ) និងប្រព័ន្ធខេមបូឌានស៊ែស្វីច
( Cambodian Shared Switch )

ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអំពីការរៀបចំទ្រង់ទ្រាយសណ្ឋាន និងពណ៌របស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ដូចខាងក្រោម៖

## ១. ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស ( Fast Payment )

### ១.១. លក្ខណៈសម្គាល់

ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស(Fast Payment) មានរាងចតុកោណកែងផ្ទៃពណ៌ក្រហមក្រមៅ ដែលមានរូប "ធ្នូនិងព្រួញ" ពណ៌ស នៅចំកណ្តាលផ្នែកខាងលើ និងមានចារឹកអក្សរ "**សេវាទូទាត់រហ័ស**" នៅផ្នែកខាងក្រោមនៃនិមិត្តសញ្ញា។ ដងធ្នូត្រូវបានរចនាឡើងជាអក្សរ "រ" តំណាងឱ្យប្រាក់រៀលដែលជារូបិយវត្ថុជាតិ និងរំលេចដោយក្បាច់បុរាណខ្មែរ។ ចំណែកឯ រូបសញ្ញា "ព្រួញ" មានអត្ថន័យសំដៅដល់ការបញ្ជូនមូលនិធិយ៉ាងឆាប់រហ័សពីភាគីផ្ញើទៅភាគីទទួល។

*រូបភាពទី១ ៖ ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment)*

សេវាទូទាត់រហ័ស

### ១.២. ពណ៌នៃស្លាកសញ្ញា

ពណ៌នៃស្លាកសញ្ញានេះគឺពណ៌ក្រហមក្រមៅ ដែលមានពណ៌គោលដូចខាងក្រោម៖

- *ពណ៌ក្រហមក្រមៅ* **C: 28 M: 99 Y: 89 K: 32**

## ២. ស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច ( Cambodian Shared Switch )

### ២.១. លក្ខណៈសម្គាល់

ស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) មានរាងចតុកោណ ផ្ទៃពណ៌ស និងមានបន្ទាត់ជុំវិញពណ៌ខៀវ ដែលមានអក្សរ "CSS" នៅចំកណ្ដាល លម្អដោយចម្លាក់ជាវចនាបទអង្គរពណ៌ប្រផេះស្រាលនៅតែមខាងលើនិងខាងក្រោម។ អក្សរ "C" មានពណ៌ខៀវ អក្សរ "S" បន្ទាប់មានពណ៌ក្រហម និងអក្សរ "S" ចុងក្រោយមានពណ៌ខៀវ។

***រូបភាពទី២ ៖ ស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)***

### ២.២. ពណ៌នៃស្លាកសញ្ញា

ពណ៌នៃស្លាកសញ្ញានេះគឺពណ៌ខៀវ ក្រហម និងប្រផេះដែលមានពណ៌គោលដូចខាងក្រោម៖

- *ពណ៌ខៀវ* C: 100 M: 90 Y: 00 K: 00
- *ពណ៌ក្រហម* C: 00 M: 100 Y: 100 K: 00
- *ពណ៌ប្រផេះ* C: 00 M: 00 Y: 00 K: 25

### ២.៣. ការប្រើប្រាស់ស្លាកសញ្ញា

#### ២.៣.១. ការបោះពុម្ពលើប័ណ្ណទូទាត់សងប្រាក់

ចំពោះការចេញផ្សាយប័ណ្ណ Proprietary Card គ្រឹះស្ថានជាសមាជិកត្រូវបោះពុម្ពស្លាកសញ្ញាប្រព័ន្ធ CSS នៅផ្ទៃខាងមុខផ្នែកខាងក្រោមជ្រុងខាងស្ដាំនៃប័ណ្ណ។ ចំណែកឯប្រភេទប័ណ្ណ Co-badge ស្លាកសញ្ញាប្រព័ន្ធ CSS នឹងស្ថិតនៅផ្ទៃខាងក្រោយផ្នែកខាងក្រោមជ្រុងខាងស្ដាំនៃប័ណ្ណ។

#### ២.៣.២. ការបិទស្លាកសញ្ញានៅតាមម៉ាស៊ីន ATM និង/ឬ POS

គ្រឹះស្ថានជាសមាជិកត្រូវបិទស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ដូចបានកំណត់ខាងលើ តាមម៉ាស៊ីន ATM និង/ឬ POS នៅទីតាំងដែលងាយកត់សម្គាល់។

## ៣. ទម្រង់នៃស្លាកសញ្ញា

ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) នឹងត្រូវពង្រីកឬបង្រួមទំហំតាមសមាមាត្រទម្រង់របស់ស្លាកសញ្ញាដែលបានកំណត់ខាងលើ។

### ៣.១. ស្លាកសញ្ញានៃប្រព័ន្ធ (Fast Payment)

ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) ត្រូវបានកំណត់ទម្រង់ស្តង់ដារដូចខាងក្រោម៖




ទម្រង់សមាមាត្រស្តង់ដារនៃស្លាកសញ្ញានេះត្រូវបានបែងចែកដោយមានប្រវែងទទឹងស្មើនឹង 5X និងប្រវែងបណ្តោយស្មើនឹង $(6 + \frac{1}{2})$ X ចំណែកឯ អក្សរ “រ” មានប្រវែង $(4 + \frac{3}{4})$ X ក្នុងនោះ X =1។

### ៣.២. ស្លាកសញ្ញានៃប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)

ស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ត្រូវបានកំណត់ទម្រង់ស្តង់ដារដូចខាងក្រោម៖




ទម្រង់សមាមាត្រស្តង់ដារនៃស្លាកសញ្ញានេះត្រូវបានបែងចែកដោយមានប្រវែងទទឹងស្មើនឹង $(4 + \frac{2}{3})$ X និងប្រវែងបណ្តោយស្មើនឹង $(8 + \frac{1}{3})$ X ចំណែកឯ X =1 ។